01032297 E314/10

នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
អង្គជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូង

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Oct-2014, 14:35
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង (អង្គជំនុំជម្រះពិសេស) |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានសេចក្តីសម្រេចឆាប់រហ័សលើបណ្តឹងជំទាស់ចៅក្រម

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកNicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះពិសេស**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ហ៊ួត វុទ្ធី
ចៅក្រម Chang-ho CHUNG
ចៅក្រម ប្រាក់ គិមសាន

**ចម្លងជូន:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ខៀវ សំផន បានដាក់បណ្តឹងមួយជូនអង្គជំនុំជម្រះសាលាដំបូង ស្វែងរកការផ្អាកដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២/០២ ឬជាជម្រើសផ្សេងទៀត សុំប្តឹងជំទាស់លោកចៅក្រម និល ណុន និងលោកស្រីចៅក្រម Silvia Cartwright , លោកចៅក្រម យ៉ា សុខន, លោកចៅក្រម JEAN-MARC Lavergne, លោកចៅក្រម យូរ ឧត្តរា, និងលោកចៅក្រម Claudia Fenz មិនឲ្យចូលរួមសវនាការជំនុំជម្រះក្នុងសំណុំរឿង០០២/០២[1]។ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងអំណះអំណាងទាំងពីរ នៅក្នុងបណ្តឹងនោះ ហើយបានបង្ហាញអំពីទស្សនៈរបស់ខ្លួនអំពី ហេតុអ្វីបានជាមិនអនុញ្ញាតចំពោះបណ្តឹងជំទាស់នេះ[2]។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ ខៀវ សំផន ដែលសុំឲ្យផ្អាកដំណើរការនីតិវិធី ហើយបញ្ជូនបណ្តឹងជំទាស់នេះទៅអង្គជំនុំជម្រះពិសេស[3]។

២- កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ នួន ជា បានដាក់បណ្តឹងមួយជូនអង្គជំនុំជម្រះពិសេស ដែលប្តឹងជំទាស់លោកចៅក្រម និល ណុន, លោកចៅក្រម យ៉ា សុខន, លោកចៅក្រម JEAN-MARC Lavergne, និងលោកចៅក្រម យូរ ឧត្តរា[4]។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ការិយាល័យសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបមួយទៅនឹងបណ្តឹងជំទាស់ចៅក្រមរបស់ នួន ជា[5]។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ខៀវ សំផន បានដាក់បណ្តឹងជំទាស់លោកចៅក្រម និល ណុន

[1] ឯកសារលេខ **E314/1** សំណើរបស់ ខៀវ សំផន សុំអោយពិនិត្យឡើងវិញអំពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿងលេខ 002/01 ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង002/02 និងសុំឲ្យពិនិត្យឡើងវិញអំពីការការចាត់តាំងក្រុមជំនុំជម្រះថ្មីមួយ, ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤។

[2] ឯកសារលេខ **E314/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬ ប្តឹងជំទាស់ចៅក្រម , ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤។

[3] ឯកសារលេខ **E314/5** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន ដែលសុំពន្យារពេលការចាប់ផ្តើមនៃសំណុំរឿង002/02 ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤។

[4] ឯកសារលេខ **E314/6** បណ្តឹងជំទាស់របស់ នួន ជា លើចៅក្រម និល ណុន, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne និង ចៅក្រម យូរ ឧត្តរា ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។

[5] ឯកសារលេខ **E314/9** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងជំទាស់របស់ នួន ជា, ចុះថ្ងៃទី១០ ខែតុលា ២០១៤។

និងលោកចៅក្រម យ៉ា សុខន, លោកចៅក្រម JEAN-MARC Lavergne, លោកចៅក្រម យូរ ឧត្តរា និងលោកចៅក្រម Claudia Fenz[6]។

៣- កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ សេចក្តីសន្និដ្ឋានចោទប្រកាន់ត្រូវបានធ្វើឡើងក្នុងសំណុំរឿង ០០២/០២។ នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់នេះ នួន ជា បានប្រកាសថា គាត់បានណែនាំដល់មេធាវីការពារក្តីរបស់គាត់មិនអោយចូលរួមនៅក្នុងសវនាការ រហូតដល់អង្គជំនុំជម្រះពិសេសចេញសេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់គាត់សិន[7]។ ខៀវ សំផន នៅក្នុងសេចក្តីថ្លែងរបស់គាត់ទាក់ទងនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ បានប្រកាសថា គាត់បានណែនាំមេធាវីការពារក្តីរបស់គាត់អោយផ្តោតទៅលើបណ្តឹងសាទុក្ខរបស់គាត់ ដែលកំពុងតែបន្តនៅក្នុងសំណុំរឿង002/01 និងមិនអោយចូលរួមនៅក្នុងសវនាការជំនុំជម្រះក្នុងសំណុំរឿង002/02 រហូតដល់ក្រោយពេលសារណាបណ្តឹងសាទុក្ខត្រូវបានបញ្ចប់[8]។ មេធាវីការពារក្តីរបស់ជនជាប់ចោទ តាមរយៈសកម្មភាព និងសេចក្តីថ្លែងរបស់គាត់ បានបញ្ជាក់អំពីបំណងអនុវត្តតាមការណែនាំទាំងនេះ។

៤- សហព្រះរាជអាជ្ញាដាក់សំណើសុំនេះ ដើម្បីឲ្យមានសេចក្តីសម្រេចជាបន្ទាន់មួយលើញត្តិរបស់មេធាវីការពារក្តីដែលប្តឹងជំទាស់ចៅក្រម អំពីបញ្ហាទាំងនេះ។

## II. **សំណើ**

៥- ខណៈដែលសហព្រះរាជអាជ្ញាយល់ឃើញថា ការជំនុំជម្រះក្តីលើសំណុំរឿង០០២/០២ អាចបន្តធ្វើដោយចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលបណ្តឹងជំទាស់ចៅក្រមកំពុងស្ថិតក្នុងការរង់ចាំការសម្រេច ដោយអនុលោមតាមវិធាន៣៤(៥) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាក៏សន្និដ្ឋានផងដែរថា ការទទួលបាននូវសេចក្តីសម្រេចមួយលើបណ្តឹងជំទាស់ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន គឺជាផលប្រយោជន៍សម្រាប់គ្រប់ភាគីទាំងអស់។ ដូច្នេះ ដើម្បីពន្លឿនសេចក្តីសម្រេចលើបញ្ហានេះឲ្យឆាប់ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះពិសេសចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងជំទាស់ចៅក្រមឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយធ្វើសម្អាងហេតុ

---

[6] ឯកសារលេខ **E314/8** បណ្តឹងជំទាស់ចៅក្រមសាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ន នៃអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើសំណុំរឿង002/02, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។

[7] សេចក្តីព្រាងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ទំព័រ ៧៣។

[8] សេចក្តីព្រាងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ទំព័រ ៧៦ និង ៧៨។

តាមក្រោយ។ នីតិវិធីនេះធ្លាប់ត្រូវបានប្រើប្រាស់ពីមុន ដើម្បីពន្លឿនសេចក្ដីសម្រេច ដោយអង្គជំនុំជម្រះជាច្រើននៃតុលាការនេះ រួមទាំងអង្គបុរេជំនុំជម្រះផង[9] ហើយក៏គួរតែត្រូវបានប្រើប្រាស់នៅទីនេះដែរ។ ដើម្បីផលប្រយោជន៍នៃការពន្លឿននេះផងដែរ សហព្រះរាជអាជ្ញាជូនដំណឹងដល់អង្គជំនុំជម្រះពិសេសថា សហព្រះរាជអាជ្ញានឹងមិនធ្វើ ចម្លើយតបទៅនឹងបណ្ដឹងជំទាស់របស់ ខៀវ សំផន ដែលបានចុះកាលបរិច្ឆេទនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ទេ។ នៅក្នុងបញ្ហានោះ សហព្រះរាជអាជ្ញាចាត់ទុកថា អំណះអំណាងនានាដែលបានបង្ហាញដោយ ខៀវ សំផន គឺបានលើកឡើងគ្រប់គ្រាន់អស់ហើយនៅក្នុងសេចក្ដីសន្និដ្ឋានពីមុនៗរបស់សហព្រះរាជអាជ្ញា ស្ដីពីបញ្ហានេះ[10]។

## III. ដំណោះស្រាយដែលស្នើសុំ

៦- ចំពោះមូលហេតុទាំងឡាយនេះ សហព្រះរាជអាជ្ញាស្នើដោយគោរពដល់អង្គជំនុំជម្រះពិសេស ឱ្យចេញសេចក្ដីសម្រេចរបស់ខ្លួនលើលើបណ្ដឹងជំទាស់ចៅក្រម ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយធ្វើសម្អាងហេតុតាមក្រោយ។៚

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

---

[9] *សូមអាន, ឧទា.* **D427/2/12**, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, ត្រង់ ENG ERN 00634920។ **D427/4/14** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, ត្រង់កថាខណ្ឌទី៣។ **D56/19/38**, [កោសលុប] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបដិសេធការតែងតាំងលោក អាង ឧត្តម និងលោក Michael KARNAVAS មិនឱ្យធ្វើជាសហមេធាវីរបស់គាត់, ១៧ កក្កដា ២០១៤, ត្រង់កថាខណ្ឌទី២១។ *សូមអាន ផងដែរ* **E116/1/6**, សេចក្ដីសង្ខេបនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ៣០ មករា ២០១២, ត្រង់ ENG ERN 00772887។

[10] **E314/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬប្ដឹងជំទាស់ចៅក្រម, ៤ កញ្ញា ២០១៤។ **E314/9** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងជំទាស់ចៅក្រមរបស់ នួន ជា, ១០ តុលា ២០១៤។